ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## សម្រេច

**ប្រការ ១:** កែសម្រួលសមាសភាពគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដូចតទៅ ៖



www.pheakdeylaw.com

| | | |
|---|---|---|
| ១-ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២-ឯកឧត្តម ម៉ឹង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុច បូរិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម ជូ គីមឡេង | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥-ឯកឧត្តម ឃឹម ស្រៀដា | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦-ឯកឧត្តម សែម សុវណ្ណនី | អគ្គនាយក មជ្ឈមណ្ឌលជាតិ | អនុប្រធាន |
| ៧-ឯកឧត្តម ណឹម សុវត្ថិ | ទីប្រឹក្សានិងជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ | សមាជិកអចិន្ត្រៃយ៍ |
| ៨-ឯកឧត្តម សុខ ផេង | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៩-ឯកឧត្តម ស្លូត សំបូរ | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០-ឯកឧត្តម ប៊ុន នី | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម សំ វណ្ណថន | អគ្គលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១២-ឯកឧត្តម ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| ១៣-ឯកឧត្តម ចៅ ភិរុណ | អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ-បច្ចេកទេសក្រសួងការពារជាតិ | សមាជិក |
| ១៤-ឯកឧត្តម មាស សារ៉ែន | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ | សមាជិក |
| ១៥-ឯកឧត្តម ជាំ វុទ្ធី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៦-ឯកឧត្តម មាស សំអុល | នាយក នាយកដ្ឋានបុគ្គលិកក្រសួងការពារជាតិ | សមាជិក |
| ១៧-ឯកឧត្តម វង្ស វិសនា | នាយកទីចាត់ការកលយុទ្ធ កងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៨-ឯកឧត្តម គង់ ឈួន | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក ។ |

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*